ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ សុក្រ ១៣ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី លទ្ធផលនៃការវាយតម្លៃបឋមលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា របស់ក្រុមការងារបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នារសៀលថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារវាយតម្លៃបឋមលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា របស់ក្រុមការងារបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

តាមការវាយតម្លៃរបស់ IMF, ទោះបីជាកំណើនសេដ្ឋកិច្ចសកលមានការថមថយក្តី, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០១៩ នៅតែសម្រេចបាននូវកំណើនរឹងមាំ ក្នុងរង្វង់អត្រា ៧,០ ភាគរយ ដែលត្រូវបានគាំទ្រដោយការបន្តកំណើនខ្ពស់នៃការនាំចេញ និងវិស័យសំណង់ ខណៈដែលអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាបប្រមាណ ២,៥ ភាគរយ ។ ទន្ទឹមនេះ, ស្ថានភាពហិរញ្ញវត្ថុសាធារណៈនៅបន្តស្ថិតក្នុងភាពល្អប្រសើរ ស្របពេលដែលបំណុលសាធារណៈ ស្ថិតក្នុងកម្រិតហានិភ័យទាបដែលអាចគ្រប់គ្រងបាន ។

ជាមួយគ្នានេះ, ក្រុមការងារបេសកកម្ម Article IV នៃ IMF ក៏បានជម្រាបជូនអង្គប្រជុំអំពីនិន្នាការថមថយនៃកំណើនសេដ្ឋកិច្ចសកល និងតំបន់ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ដោយសារការកើនឡើងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម និងការកើនឡើងគោលនយោបាយគាំពារនិយម (Protectionism) ។ ប៉ុន្តែ, ក្រុមការងារ IMF ក៏បានគូសរំលេចផងដែរថាសង្គ្រាមពាណិជ្ជកម្មបានផ្តល់ផលវិជ្ជមានមួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃការនាំចេញ ជាពិសេស ទៅសហរដ្ឋអាមេរិក និងលំហូរទុនវិនិយោគពីបរទេស ។ ក្នុងឆ្នាំ ២០២០, សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងថមថយបន្តិច ដោយសារការថយចុះកំណើននៃសេដ្ឋកិច្ចសកល ។

បន្ថែមលើនេះ, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រួមជាមួយកំណើនសេដ្ឋកិច្ចខ្ពស់ និងការបន្តធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់កម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ដល់វឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ។ ទោះជាយ៉ាងនេះក្តី, សេដ្ឋកិច្ចកម្ពុជា ក៏កំពុងប្រឈមនឹងហានិភ័យខ្ពស់ជាងមុន ដែលបណ្តាលមកពីការកើនឡើងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម និងលទ្ធភាពនៃការដកប្រព័ន្ធអនុគ្រោះពន្ធ (EBA) ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ។

យ៉ាងណាមិញ, IMF បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតនៅលើមាគ៌ាត្រឹមត្រូវក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន រួមទាំង ការគ្រប់គ្រងប្រមូលចំណូល ជាពិសេស កិច្ចខិតខំប្រឹងប្រែងផ្នែករដ្ឋបាលសារពើពន្ធ និងការកែទម្រង់ផ្នែកតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ សំដៅដោះស្រាយបញ្ហាប្រឈម និងបញ្ចៀសរាល់ហានិភ័យដែលអាចកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញនូវកញ្ចប់ថវិកាចំណាយបន្ថែមក្នុងឆ្នាំ ២០២០ ដើម្បីគាំទ្រដល់ការបង្កើតការងារ, ការអភិវឌ្ឍធនធានមនុស្ស និងបង្កើនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ។ ទន្ទឹមនេះ, វិធានការទាំងនេះ ក៏បានផ្តោតលើការលើកកម្ពស់ការប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជាផងដែរ ។ ស្របពេលជាមួយគ្នានេះដែរ, IMF ក៏បានលើកទឹកចិត្ត និងជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាពន្លឿនការអនុវត្តវិធានការកំណែទម្រង់ទាំងនេះ សំដៅសម្រេចបានសមិទ្ធផលប្រកប ដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបេសកកម្ម Article IV នៃ IMF ក្នុងការវាយតម្លៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងដាក់ចេញនូវអនុសាសន៍គោលនយោបាយ និងការបន្តផ្តល់ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពមន្ត្រីកម្ពុជាឱ្យកាន់តែមានជំនាញ និងចំណេះដឹងប្រសើរជាងមុន ជាពិសេស ការផ្តល់ជំនួយបច្ចេកទេសលើការចងក្រងស្ថិតិជារួមរបស់រាជរដ្ឋាភិបាល ដែលមានសារៈសំខាន់សម្រាប់ការវិភាគ, វាយតម្លៃ និងរៀបចំគោលនយោបាយប្រកបដោយប្រសិទ្ធភាព ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងាររបស់ក្រុមការងារបេសកកម្ម Article IV នៃ IMF និងជូនពរក្រុមការងារឱ្យធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុខសុវត្ថិភាព ។